ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣២/២១ - យ៉ុង រ៉ុង ហ៊ែនប៊ែក ឯ.ក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ ហែម ហួណារិទ្ធ
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ហួន ជុនឌី
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លះ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន យ៉ុង រ៉ុង ហ៊ែនប៊ែក ឯ.ក**
អាសយដ្ឋាន ៖ ភូមិក្រងស្វាយ ឃុំស្វាយរំពារ ស្រុកមុខកំពូល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៧៦ ៦០ ៦៧ ៩៦៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖
១-លោក វ៉ន ចាន់ថារិទ្ធិ ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ុង រ៉ុង ហ៊ែនប៊ែក ឯ.ក**
អាសយដ្ឋាន ៖ ភូមិក្រងស្វាយ ឃុំស្វាយរំពារ ស្រុកមុខកំពូល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៥ ៥៨ ៨៣ ៣៨ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖ អវត្តមាន។

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំក្រុមហ៊ុនផ្តល់លុយបាយ ១៥ដុល្លារអាមេរិក ក្នុងមួយខែ ថ្លៃទឹកដោះគោកូន ជំនួសការដែលក្រុមហ៊ុនគ្មានទារកដ្ឋាន និងគ្មានអ្នកមើលក្មេង។

២- ស្នើសុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលឱ្យបានត្រឹមត្រូវ ជាពិសេសប្រាក់ឈ្នួលថ្ងៃបុណ្យ និងថ្ងៃអាទិត្យ។

៣- ស្នើសុំក្រុមហ៊ុនបើកលុយថ្លៃបាយធ្វើការថែមម៉ោង ក្នុង១សប្តាហ៍ម្តង គឺរៀងរាល់ថ្ងៃចន្ទ។

៤- ស្នើសុំក្រុមហ៊ុនពេលកម្មករដេរខុស ហើយត្រូវកែផលិតផលដែលដេរខុសនោះសូមគិតប្រាក់ឈ្នួលឱ្យកម្មករតាមអត្រាធ្វើការថែមម៉ោងមិនត្រូវកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់កម្មករឡើយ។

៥- ស្នើសុំពេលកម្មករឈឺមានសំបុត្រពេទ្យបញ្ជាក់ត្រឹមត្រូវ សូមក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ។

៦- ស្នើសុំក្រុមហ៊ុនរៀបចំឱ្យកម្មករបានប្រើប្រាស់សេវារបបសន្តិសុខសង្គម (ប.ស.ស) ពេលកម្មករឈឺ ឬជួបគ្រោះថ្នាក់ដោយប្រការណាមួយ។

៧- ស្នើសុំក្រុមហ៊ុនជួយណែនាំប្រធានក្រុម ប្រធានផ្នែក (បុគ្គល) ឱ្យមានកាយវិការពាក្យសម្ដីសមរម្យមកលើកម្មករ។

៨- ស្នើសុំនៅពេលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិត ក្រុមហ៊ុនត្រូវទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនពួកគាត់ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ។

៩- ស្នើសុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ២ដង ក្នុង១ខែ។

១០- ស្នើសុំក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពីកម្មករ ដែលជាសមាជិកសហជីពសិទ្ធិប្រយោជន៍កម្មករ ហើយយល់ព្រមឱ្យកាត់តាមតារាងឧបសម្ព័ន្ធសុំចូលជាសមាជិក ដើម្បីបង់ប្រាក់ភាគទានសហជីព។

១១- ស្នើសុំក្រុមហ៊ុនកុំរើសអើងស្ត្រីមានផ្ទៃពោះ បញ្ឈប់ស្ត្រីមានផ្ទៃពោះ និងត្រូវផ្តល់ប្រាក់ឈ្នួលអត្ថប្រយោជន៍ផ្សេងៗ ជូនស្ត្រីឈប់សម្រាកលំហែមាតុភាពឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ។

១២- ស្នើសុំពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ ក្រុមហ៊ុនមិនត្រូវរំសាយកម្មករ ដោយមិនបានព្យួរការងារជាមុននោះទេ។

១៣- ស្នើសុំក្រុមហ៊ុនពេលកាត់បន្ថយកម្មករ ក្រុមហ៊ុនត្រូវទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនពួកគាត់ឱ្យបានត្រឹមត្រូវតាមច្បាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ុង រ៉ុង ហែនបែក ឯ.ក លេខ ៧១៥ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពីការទាមទាររបស់កម្មករនិយោជិត សុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ១៣ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា។ ចំណុចមិនសះជាចំនួន ១៣ ចំណុច ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ុង រ៉ុង ហ៊ែនប៊ែក ឯ.ក លេខ ៧១៩ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើកណីមិនសះជាចំនួន ១៣ ចំណុច នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក តាមរយៈលិខិតអញ្ជើញលេខ ១៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ១៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ទៅភាគីកម្មករនិយោជិត ដោយភាគីទាំងពីរបានឆ្លើយតបតាមរយៈទូរសព្ទ និងប្រព័ន្ធតេឡេក្រាម ពីការទទួលបានការញ្ជើញនេះ ប៉ុន្តែសវនាការត្រូវបានលើកពេលតាមរយៈការស្នើសុំរបស់ក្រុមអាជ្ញាកណ្ដាល និងកំណត់ថ្ងៃសវនាការថ្មីនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទីរសៀល។ ភាគីនិយោជក និងភាគីកម្មករនិយោជិតឯកភាពតាមការស្នើសុំរបស់ក្រុមអាជ្ញាកណ្ដាល។

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញលើកទី២ អញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើកណីមិនសះជាចំនួន ១៣ ចំណុច នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀលតាមរយៈលិខិតអញ្ជើញលេខ ១៩៤ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ១៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ភាគីកម្មករនិយោជិត។ ភាគីទាំងពីរបានឆ្លើយតបតាមរយៈទូរសព្ទ និងប្រព័ន្ធតេឡេក្រាម ពីការទទួលបានការញ្ជើញលើកទី២នេះ។

នៅថ្ងៃសវនាការ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចន្លោះពីម៉ោង ៩ ទៅ ១០ព្រឹក មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទំនាក់ទំនងតាមទូរសព្ទ និងផ្ញើសារតាមរយៈប្រព័ន្ធតេឡេក្រាមទៅកាន់លោក រុន រី ដែលជាប្រធានសហជីពសិទ្ធិប្រយោជន៍កម្មករនៃក្រុមហ៊ុន យ៉ុង រ៉ុង ហ៊ែនប៊ែក ឯ.ក និងជាតំណាងភាគីកម្មករនិយោជិត ដើម្បីរំលឹកពីថ្ងៃសវនាការ ប៉ុន្តែលោកមិនបានទទួលទូរសព្ទ និងមិនបានចូលអានសារនៅក្នុងប្រព័ន្ធតេឡេក្រាមនោះទេ។ បន្ទាប់មក នៅវេលាម៉ោង ១៤ និង ០០ នាទីរសៀល នៅថ្ងៃដដែល មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទំនាក់ទំនងតាមទូរសព្ទម្ដងទៀតទៅលោក រុន រី ប៉ុន្តែនៅតែមិនមានការឆ្លើយតប

THE ARBITRATION COUNCIL

ដដែល។ បន្ថែមពីនេះ នៅថ្ងៃសវនាការ លោក វន ចាន់ថារិទ្ធ បានផ្តល់ព័ត៌មានមកមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងបានឈប់ធ្វើការនៅក្នុងក្រុមហ៊ុន និងបានទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗរួចអស់ហើយ ដូច្នេះ ភាគីកម្មករនិយោជិតនឹងមិនមកចូលរួមសវនាការនោះទេ។ ដូច្នេះក្រុមអាជ្ញាកណ្តាលសម្រេចបើកសវនាការដោយអវត្តមានរបស់ភាគីកម្មករនិយោជិត។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមហ៊ុន យ៉ុង រ៉ុង ហៃនវ៉ែក ឯ.ក គោរពជូនលោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក វន ចាន់ថារិទ្ធិ តួនាទីជាប្រធានផ្នែករដ្ឋបាលប្រចាំក្រុមហ៊ុន យ៉ុង រ៉ុង ហៃនវ៉ែក ឯ.ក។

២- តារាងបើកប្រាក់ឈ្នួល។

៣- លិខិតជូនដំណឹងបញ្ចប់កិច្ចសន្យា និងលិខិតលាឈប់ការងារ ឈ្មោះ កន ចិត្រា, ផាន សារឿន, ជិន សុខលាង និង រុន រី ។

៤- សារណាសង្ខេប ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ុង រ៉ុង ហៃនវ៉ែក ឯ.ក លេខ ៧១៩ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន យ៉ុង រ៉ុង ហៃនវ៉ែក ឯ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ុង រ៉ុង ហៃនវ៉ែក ឯ.ក លេខ ០០៧/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៨៦ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៨៧ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៩៤ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨ កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៩៥ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ុង រ៉ុង ហ៊ែនប៊ែក ឯ.ក ដែលបញ្ជូនមកដោយនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ ដោយហេតុថា ភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងមិនបានចូលរួមនីតិវិធីក្នុងសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានរបស់ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹង?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ "*ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត*"។

ប្រការ ២០ នៃប្រកាសដដែល ចែងថា ៖ "*...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម*"។

ប្រការ ២១ នៃប្រកាសដដែល ចែងថា ៖ "*ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ ហើយតែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់*"។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ "*ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌ ថាភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន*"។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា លក្ខខណ្ឌបីត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ, លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣០/០៥-មូរៀ, លេខ ១៦/០៧-ឡូទូសតិ៍, លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣,*

*លេខ ៩៥/ ០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិលសិន, លេខ ០៩/០៩-នីមបឹស ថិចថាយ៍, លេខ ០១/១០-ខិននីតិក, លេខ ៣០/១០-គួរ៉េស អាប៉ារ៉ែល, លេខ ១៣០/១៣-យែនផើរេន អ៊ីកែវីល, លេខ ១៦៧/១៣-យូ៊ីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល លេខ ២៧០/១៣-៨ ស្តារស្គត់វ៉ែ, លេខ១៥៦/១៥-ជេនើរេសិន អ៊ិនធើណេសិនណល, លេខ ៣៣៨/១៥-ហ្វូខឹស ម៉េត (ខេមបូឌា) លេខឌីហ្គូដ មេនូហ្វេធឺរីង លីមីធីត, លេខ០៤៦/១៨-រូស៊ីង ហ្គាម៉ែន (សាខាទី១), លេខ ០៥៥/១៨-សេឌូណូ អ៊ិនវេសមេន ខេមបូ ហ្វេសិន, លេខ ០២២/២១-ញូហ្វ៊ូម៉ា២ ខសញ្ញម )*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញដែរ ឬទេ ?

*លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ*

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលើកទី២ លេខ ១៩៥ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ។ នៅក្នុងលិខិតនោះ បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ គឺនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញត្រឹមត្រូវ ពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមន្ត្រីលេខាធិការដ្ឋានបានធ្វើការទាក់ទងទៅភាគីទាំងពីរ តាមរយៈទូរសព្ទ និងប្រព័ន្ធតេឡេក្រាម ហើយភាគីទាំងពីរបានឆ្លើយតបពីការទទួលបានការញ្ជើញឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងបានទទួលការអញ្ជើញពីក្រុមអាជ្ញា-កណ្តាលតាមរយៈមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រឹមត្រូវ ស្របតាមខ្លឹមសារប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃ ទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើនេះទេ។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

*លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា យោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលតម្រូវឱ្យភាគីត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលនោះ គឺភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនមានវត្តមាននៅក្នុងសវនាការទេ។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទាក់ទងទៅកាន់តំណាងកម្មករនិយោជិត គឺលោក

ន វ ដើម្បីរំលឹកពីថ្ងៃសវនាការ ប៉ុន្តែមិនទទួលបានការឆ្លើយតបនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ស្របតាមខ្លឹមសារប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃ ទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើនេះទេ។ ដូចនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការ និងមិនបានឆ្លើយតបតាមរយៈទូរសព្ទ និងប្រព័ន្ធតេឡេក្រាម ដែលមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទំនាក់ទំនងទៅនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ នោះទេ។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើមបណ្តឹងមិនបានផ្តល់ហេតុផលត្រឹមត្រូវណាមួយ សម្រាប់ការមិនមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមខ្លឹមសារប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃ ទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សា-អាជ្ញាកណ្តាលខាងលើនេះទេ។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃ ទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ខាងលើ ត្រូវបានបំពេញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តាមនីតិវិធីនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីដើមបណ្តឹង និងភាគីចុងចម្លើយនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល មានកាតព្វកិច្ចបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញ និងផ្តល់អំណះអំណាង សម្រាប់ការទាមទាររបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញា-កណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងចម្លើយមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួន ពីការទាមទារពីសំណាក់ដើមបណ្តឹង។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹង មិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលចាត់ទុកថា ភាគីដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្តាលនោះទេ។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៣២/២១-ក្រុមហ៊ុន យ៉ុង រ៉ុង ហៃនប៊ែក ឯ.ក នេះ។

THE ARBITRATION COUNCIL

## សម្រេច និង បង្គាប់

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ០៣២/២១ - ក្រុមហ៊ុន យ៉ុង រ៉ុង ហៃនប៊ែក ឯ.ក ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **ហែម ហួរណារិទ្ធិ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ហួន ជុនឌី**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL